ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# ដំណាំស្ពៃក្តោបក្នុងផ្ទះសំណាញ់



រៀបចំដោយ


**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ.ជ.ក)**


ខែមេសា ឆ្នាំ២០២៥

# មាតិកា

១-សេចក្តីផ្តើម...................................................................................................................១
២-ការអនុវត្តការដាំដុះ.........................................................................................................១
ក-ការរៀបចំដី.............................................................................................................១
ខ-ល្បាយដីបណ្តុះកូន....................................................................................................១
គ-ការរៀបចំប្រព័ន្ធទឹក...................................................................................................១
ឃ-ការជ្រើសរើសពូជ.....................................................................................................១
ង-វិធីដាំដុះ.................................................................................................................២
ច-ការថែទាំ.................................................................................................................២
ឆ-ការដាក់ជី................................................................................................................២
ជ-កត្តាចង្រៃ...............................................................................................................២
ឈ-អាយុកាលដាំដុះ និងប្រមូលផល.................................................................................៤
៣-តម្រូវការទុនដំបូងក្នុងការដាំដុះស្ពៃក្តោបក្នុងផ្ទះសំណាញ់ទំហំ ២៥០ ម៉ែត្រការ៉េ........................៤
៤-ការវិភាគសេដ្ឋកិច្ចលើការដាំដុះស្ពៃក្តោបក្នុងផ្ទះសំណាញ់ទំហំ ២៥០ ម៉ែត្រការ៉េ..........................៤
៥-លទ្ធភាពចំណេញផ្អែកលើនិន្នាការតម្លៃលើផ្ទៃដីដាំដុះ២៥០ ម៉ែត្រការ៉េ.......................................៥
៦-ខ្សែច្រវាក់តម្លៃ..................................................................................................................៦
៧-ហានិភ័យ........................................................................................................................៦
៨-សេចក្តីសន្និដ្ឋាន.................................................................................................................៧

# ដំណាំស្ពៃក្តោបក្នុងផ្ទះសំណាញ់

## ១-សេចក្តីផ្តើម

ស្ពៃក្តោបគឺជាបន្លែមួយប្រភេទដែលមានតម្រូវការខ្ពស់សម្រាប់ទីផ្សារ និងមានការពេញនិយមក្នុងការបរិភោគ។ កសិករកម្ពុជាបានអនុវត្តន៍ការដាំដុះដំណាំស្ពៃក្តោបជាច្រើនទាំងនៅលើទីវាល និងក្នុងផ្ទះសំណាញ់។ ការដាំស្ពៃក្តោបក្នុងផ្ទះសំណាញ់គឺជាវិធីសាស្រ្តដ៏ទំនើប ដែលអាចជួយកសិករកាត់បន្ថយការប្រើប្រាស់សារធាតុគីមី និងធានាបាននូវគុណភាពដំណាំ។ ផ្ទះសំណាញ់អាចការពារដំណាំពីសត្វល្អិត និងកត្តាអាកាសធាតុមិនអំណោយផល ដែលជាកត្តាសំខាន់ក្នុងការដាំដុះបានគ្រប់រដូវកាល។

## ២-ការអនុវត្តការដាំដុះ

**ក. ការរៀបចំដី÷** កសិករត្រូវសាងសង់ផ្ទះសំណាញ់ ដែលសមស្របទៅតាមសណ្ឋានដីជាក់ស្តែង ប៉ុន្តែបណ្តោយផ្ទះសំណាញ់មិនគួរវែងជាង៥០ម៉ែត្រឡើយ ដោយសារសមត្ថភាពបញ្ជូនទឹករបស់ប្រព័ន្ធដំណក់ទឹកមានប្រសិទ្ធភាពនៅក្នុងចម្ងាយក្រោម៥០ម៉ែត្រ។ ក្រោយសាងសង់ផ្ទះសំណាញ់រួច កសិករត្រូវភ្ជួរដីឱ្យម៉ដ្ឋល្អ រួចហាលដីទុករយៈពេលពី ១០ ទៅ១៥ថ្ងៃ បន្ទាប់មកត្រូវឆ្វូតពូនជារងដែលមានទទឹងខ្នងលើ ១-១.២ម៉ែត្រ និងមានកម្ពស់រង ១០-២០ សង់ទីម៉ែត្រ ដោយទុកចន្លោះពីពាក់កណ្តាលរងមួយទៅពាក់កណ្តាលរងមួយប្រវែង ១.៥ម៉ែត្រ ដាំ ២-៣ជួរ ដើម្បីឱ្យស្ពៃក្តោបមានទំហំឆ្លើយតបទៅតាមតម្រូវការទីផ្សារ។ មុនពេលដាំ ត្រូវប្រើប្រាស់ជីធម្មជាតិ និងជីគីមីទ្រាប់បាត ស្របតាមបច្ចេកទេស និងគុណភាពដី។

**ខ. ល្បាយដីបណ្តុះកូន ÷** ល្បាយដីបណ្តុះកូនដំណាំស្ពៃក្តោបរួមមាន÷ ដីដំបូក ឬដីទន្លេ ១/៣ ធ្យូងអង្កាមនិងស្រកីដូងម៉ដ្ឋ ១/៣ កំប៉ុស១/៣ ដោយច្របល់ចូលគ្នា បន្ទាប់មកយកទៅលីង ឬចំហុយសម្លាប់មេរោគ និងគ្រាប់ស្មៅចង្រៃ។ កូនដំណាំស្ពៃក្តោបអាចប្រើប្រាស់វិធីការពារសត្វល្អិត និងជំងឺ ដោយប្រើប្រាស់វិធានការជីវសាស្រ្ត និងវិធានការគីមី។

**គ. ការរៀបចំប្រព័ន្ធទឹក÷** ប្រើប្រាស់ប្រព័ន្ធដំណក់ទឹកទ្រប គឺសមស្របសម្រាប់ដំណាំស្ពៃក្តោប។

**ឃ. ការជ្រើសរើសពូជ÷** កសិករអាចជ្រើសពូជស្ពៃក្តោបមួយចំនួនដែលមានវត្តមាននៅកម្ពុជា។




Green Eagle313




KNOWN YOU
Tropical Delight




East-West Seed
INDICA F1




CHIA TAI
GREEN 79

**ង. វិធីដាំដុះ៖** កសិករត្រូវយកកូនស្ពៃក្តោបដែលបណ្តុះបានអាយុពី១៨ ទៅ ២១ថ្ងៃ ពីថាសបណ្តុះមកដាំលើរងដែលបានរៀបចំហើយ ដោយដាំចន្លោះគុម្ព ៤០ស.មសម្រាប់ដាំ៣ជួរ និង៥០-៦០ស.មសម្រាប់ដាំ២ជួរលើរងតែមួយ។



**ច. ការថែទាំ៖** នៅពេលកូនដំណាំនៅតូច គប្បីតាមដានការស្រោចស្រពឱ្យបានត្រឹមត្រូវ ដើម្បីប្រាកដថាកូនដំណាំមិនខ្វះទឹក និងជំងឺរលាកគល់។ បន្ទាប់ពីដាំបានរយៈពេល៣ថ្ងៃឡើងទៅ ត្រូវមានកាលវិភាគប្រើប្រាស់ថ្នាំជីវសាស្ត្រ និងថ្នាំពុលកសិកម្មសម្រាប់បង្ការជំងឺ និងសត្វល្អិតចង្រៃផ្សេងៗជាមុន។ កសិករចាំបាច់ត្រូវមានការត្រួតពិនិត្យដំណាំជារៀងរាល់ថ្ងៃ ដើម្បីឈានដល់ការគ្រប់គ្រងកត្តាចង្រៃបានល្អប្រសើរ។ នៅពេលដែលមានកម្តៅក្តៅខ្លាំងនៅរដូវប្រាំង គប្បីប្រើប្រាស់ស្បៃការពារពន្លឺ កម្តៅ ដើម្បីឱ្យកូនដំណាំស្ពៃក្តោបមានលទ្ធភាពដុះលូតលាស់បានល្អប្រសើរ។

**ឆ. ការដាក់ជី៖** ដំណាំស្ពៃក្តោបក្រោយពេលដាំដុះលើរងរួចរាល់ ត្រូវមានកម្មវិធីប្រើប្រាស់ជីដែលបរិមាណជីគឺប្រើប្រួលទៅតាមស្ថានភាពលូតលាស់របស់ដំណាំ។ កសិករអាចប្រើប្រាស់ប្រភេទជីទឹកនៅដំណាក់កាលលូតលាស់ដោយដាក់បញ្ចូលតាមប្រព័ន្ធដំណក់ទឹក និងបាញ់បន្ថែមទៅលើស្លឹក។ សារធាតុជីចម្បងៗមានបីប្រភេទគឺ៖ N P K ដែលជាតម្រូវការចាំបាច់សម្រាប់ការដុះលូតលាស់ដំណាំស្ពៃក្តោបបានល្អ និងមានទម្ងន់ធ្ងន់។ សារធាតុបន្ថែម Trace Element(TE) ពិតជារួមចំណែកយ៉ាងសំខាន់ដល់គុណភាពផលិតផល ទិន្នផល និងរូបរាងស្រស់ស្អាត ដើម្បីបំពេញតម្រូវការទីផ្សារ។

**ជ. កត្តាចង្រៃ៖** ជាទូទៅកសិករតែងជួបប្រទះជាញឹកញាប់នូវកត្តាចង្រៃមានដូចជា៖ ដង្កូវស៊ីបណ្តូលស្ពៃ ដង្កូវយោលទោង ដង្កូវហ្វូង ទាកគូ អេហ្វីត ជំងឺរលាកគល់កូនដំណាំ និងជំងឺបាក់តេរី។


ដង្កូវស៊ីបណ្ណូល


ដង្កូវយោលទោង


ដង្កូវហ្វូង


ទាកត្ូ


អេហ្វីដ


ជំងឺផ្សិត


ជំងឺបាក់តេរី

**ឈ. អាយុកាលដាំដុះ និងប្រមូលផល**÷ស្ពៃក្តោបអាចប្រមូលផលនៅអាយុ ៩០ថ្ងៃ ក្រោយពេលបណ្តុះកូន ឬស្ពៃក្តោបមានទម្ងន់ចាប់ពី ១គីឡូក្រាមឡើងទៅ។ វិធីសាស្ត្រប្រមូលផលស្ពៃក្តោបកសិករត្រូវប្រើកាំបិតមុតកាត់ផ្តាច់គល់ កាត់ស្លឹកមួយចំនួនចេញ បន្ទាប់មកអាចច្រកក្នុងថង់ ឡាំងកេះដែលធ្វើពីជ័រ ឬក្រដាស់ស្ងួត។ ទិន្នផលស្ពៃក្តោបគឺអាស្រ័យលើចំនួនគុម្ពដែលដាំដុះក្នុងផ្ទះសំណាញ់ និងប្រភេទពូជ។

## ៣-តម្រូវការទុនដំបូងក្នុងការដាំដុះស្ពៃក្តោប ក្នុងផ្ទះសំណាញ់ទំហំ ២៥០ ម៉ែត្រការ៉េ

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) |
|---|---|
| ចំណាយលើការដាំដុះ | 640,000 |
| ចំណាយលើប្រព័ន្ធស្រោចស្រព | 4,160,000 |
| សម្ភារៈផ្សេងៗ | 10,920,000 |
| **សរុប** | **15,720,000** |

## ៤-ការវិភាគសេដ្ឋកិច្ចលើការដាំដុះដំណាំស្ពៃក្តោបក្នុងផ្ទះសំណាញ់ទំហំ ២៥០ ម៉ែត្រការ៉េ

- បទពិសោធន៍÷ ការដាំដុះរបស់កសិករនៅឃុំតាពូង ស្រុកថ្មគោល ខេត្តបាត់ដំបង
- ទិន្នផលមធ្យម÷ ១,២០០ គ.ក
- តម្លៃលក់÷ ១,៨០០រៀល/គ.ក
- ចំនួនវគ្គក្នុងមួយឆ្នាំ÷ ៣វគ្គក្នុងមួយឆ្នាំ

| បរិយាយ | ឯកតា | ចំនួនឯកតា | តម្លៃ/ឯកតា (រៀល) | ទឹកប្រាក់ (រៀល) | ចំនួនសាររំលស់ | ទឹកប្រាក់សរុប (រៀល) |
|---|---|---|---|---|---|---|
| **១-ចំណូលពីការលក់** | គ.ក | 1,200 | 1,800 | 2,160,000 | | 2,160,000 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល** | | | | | | **1,653,333** |
| **២.ក-ចំណាយប្រែប្រួលសរុប** | | | | | | 640,000 |
| ភ្ជួរដី | លើក | 2 | 20,000 | 40,000 | | 40,000 |
| ពូជ | កញ្ចប់ | 1 | 40,000 | 40,000 | | 40,000 |
| ជីកំប៉ុស (លាមកគោ) | គោយន្ត | 1 | 50,000 | 50,000 | | 50,000 |
| ជីដេអាប៉េ (18-46-0) | គីឡូ | 10 | 4,000 | 40,000 | | 40,000 |
| ជីកាលី (0-0-60) | គីឡូ | 10 | 4,000 | 40,000 | | 40,000 |

| | | | | | | |
|---|---|---|---|---|---|---|
| ថ្នាំសម្លាប់សត្វល្អិត + ជំងឺ | ឈុត | 1 | 40,000 | 40,000 | | 40,000 |
| ថ្លៃកម្មករដាំ និងថែទាំ | នាក់/ថ្ងៃ | 10 | 30,000 | 300,000 | | 300,000 |
| ថ្លៃអគ្គិសនី | វគ្គ | 1 | 60,000 | 60,000 | | 60,000 |
| ចំណាយផ្សេងៗ | វគ្គ | 1 | 30,000 | 30,000 | | 30,000 |
| **២.ខ-ចំណាយមិនប្រែប្រួលសរុប** | | | | | | 1,013,333 |
| ផ្ទះសំណាញ់(ប្រើ៥ឆ្នាំ) | ផ្ទះ | 1 | 8,000,000 | 8,000,000 | 15 | 533,333 |
| ប្រព័ន្ធទឹក (ប្រើ២ឆ្នាំ) | ឈុត | 1 | 800,000 | 800,000 | 6 | 133,333 |
| ម៉ូទ័របូមទឹក(ប្រើ៣ឆ្នាំ) | គ្រឿង | 1 | 240,000 | 240,000 | 9 | 26,667 |
| អណ្តូងទឹក (ប្រើ១០ឆ្នាំ) | គ្រឿង | 1 | 3,000,000 | 3,000,000 | 30 | 100,000 |
| ធុងបាញ់ថ្នាំ (ប្រើ៣ឆ្នាំ) | ឈុត | 1 | 120,000 | 120,000 | 9 | 13,333 |
| ម៉ាស៊ីនវាយដី (ប្រើ៥ឆ្នាំ) | គ្រឿង | 1 | 2,800,000 | 2,800,000 | 15 | 186,667 |
| កៅស៊ូស្តុកទឹក (ប្រើ២ឆ្នាំ) | ឈុត | 1 | 120,000 | 120,000 | 6 | 20,000 |
| **៣-ចំណេញសរុប** | | | | | | 506,667 |
| ថ្លៃដើមផលិត/គ.ក = ចំណាយសរុប/ទិន្នផលសរុប | | | | | | 1,378 |
| ចំណេញ/គ.ក = ចំណេញសរុប/ទិន្នផលសរុប | | | | | | 422 |

**៥-លទ្ធភាពចំណេញផ្អែកលើនិន្នាការតម្លៃ** ÷ (លើផ្ទៃដីដាំដុះ២៥០ ម៉ែត្រការ៉េ)

-តម្លៃទាបបំផុត ១,០០០៛/គ.ក

-តម្លៃខ្ពស់បំផុត ៣,០០០៛/គ.ក

| ទិន្នផល គ.ក | តម្លៃ រៀល/គ.ក | ចំណូល រៀល | ចំណាយ រៀល | ចំណេញ-ខាត | |
|---|---|---|---|---|---|
| | | | | រៀល | % |
| 1,200 | 1,000 | 1,200,000 | 1,653,333 | -453,333 | -27.42% |
| 1,200 | 1,500 | 1,800,000 | 1,653,333 | 146,667 | 8.87% |
| 1,200 | 1,800 | 2,160,000 | 1,653,333 | 506,667 | 30.65% |
| 1,200 | 2,000 | 2,400,000 | 1,653,333 | 746,667 | 45.16% |
| 1,200 | 2,500 | 3,000,000 | 1,653,333 | 1,346,667 | 81.45% |
| 1,200 | 3,000 | 3,600,000 | 1,653,333 | 1,946,667 | 117.74% |

## ៦-ខ្សែច្រវាក់តម្លៃ ៖

**កសិករ ៖** លក់ ១,៨០០៛/គ.ក - ថ្លៃដើម ១,៣៧៨៛/គ.ក = ចំណេញ ៤២២៛/គ.ក

**ឈ្មួញកណ្ដាល ៖** លក់ ២,៣០០៛/គ.ក(ថ្លៃដឹកជញ្ជូន ២០០៛/គ.ក) ចំណេញ ៣០០៛/គ.ក

**អ្នកលក់រាយ ៖** លក់៣,០០០៛/គ.ក(ជួលតូប និងខូចខាត៣០០៛/គ.ក) ចំណេញ ៤០០៛/គ.ក

## ៧-ហានិភ័យ ៖

តាមការសិក្សាផ្ទាល់ជាមួយកសិករដាំដុះស្ពៃក្ដោបនៅឃុំតាពូង ស្រុកថ្មគោល ខេត្តបាត់ដំបង អាចមានហានិភ័យមួយចំនួនកើតឡើងជាយថាហេតុលើដំណើរការដាំដុះដំណាំស្ពៃក្ដោបដូចជា៖

| ប្រភេទហានិភ័យ | ពិពណ៌នាហានិភ័យ | វិធានការ |
|---|---|---|
| **ហានិភ័យផលិតកម្ម** | ទិន្នផលធ្លាក់ចុះបណ្ដាលមកពី៖<br>-កត្តាសត្វល្អិតចង្រៃ<br>-កត្តាជំងឺដំណាំ<br>-កត្តាគុណភាពដី | -គួរប្រើប្រាស់វិធានការការពារដំណាំ និងមានកាលវិភាគប្រើប្រាស់ថ្នាំត្រឹមត្រូវសម្រាប់សត្វល្អិត និងជំងឺ<br>-ប្រើប្រាស់ថ្នាំជីវសាស្ត្រ មុនពេលចាប់ផ្ដើមដាំដុះ<br>-ជ្រើសរើសពូជធន់នឹងកត្តាចង្រៃ ពូជបង្កាត់<br>-សិក្សាការកែប្រែគុណភាពដី និងបន្ថែមការគ្រប់គ្រងជីឱ្យស្របតាមតម្រូវការជីរបស់ដំណាំស្ពៃក្ដោប ជាពិសេសដីដែលមានសារធាតុអាស៊ូតខ្ពស់ |
| **ហានិភ័យទីផ្សារ** | ពីខែកុម្ភៈ ដល់ ឧសភា មានការប្រកួតប្រជែងតម្លៃ ដោយសារការផលិតច្រើន និងអាកាសធាតុអំណោយផល | -ពង្រីកបណ្ដាញទីផ្សារឱ្យបានច្រើន និងព័ត៌មានទីផ្សារជាប្រចាំ ដើម្បីពង្រឹងទីផ្សារ<br>-ចងក្រងក្រុមផលិត ដើម្បីធ្វើកិច្ចព្រមព្រៀងទិញ-លក់ និងធ្វើផែនការផលិតតាមកិច្ចសន្យា<br>-ផលិតដំណាំចម្រុះ ជាជាងដំណាំតែមួយមុខ<br>-ស្វែងរកព័ត៌មាននៃការដាំដុះនៅតំបន់ផ្សេងៗ ដើម្បីជ្រើសរើសមុខដំណាំសម្រាប់ដាំដុះ |

## ៨-សេចក្តីសន្និដ្ឋាន

ស្ពៃក្តោបគឺជាបន្លែមួយប្រភេទដែលមានតម្លៃសេដ្ឋកិច្ចល្អ និងអាចដាំដុះបានគ្រប់រដូវកាល។ ដើម្បីបង្កើនផលិតភាព កសិករគួរប្រើប្រាស់ផ្ទះសំណាញ់សម្រាប់ការដាំដុះ ដោយសារតែអាចការពារពីសត្វល្អិត និងអាកាសធាតុដែលអាចប៉ះពាល់ដល់ដំណាំ។ ការប្រើប្រាស់ផ្ទះសំណាញ់អាចជួយកាត់បន្ថយការប្រើប្រាស់សារធាតុគីមី និងជាជម្រកដ៏ល្អសម្រាប់ដំណាំក្នុងការលូតលាស់។ ដើម្បីដាំដុះស្ពៃក្តោបក្នុងផ្ទះសំណាញ់ កសិករត្រូវជ្រើសរើសដីដែលមានសារធាតុចិញ្ចឹមល្អគ្រប់គ្រាន់ និងមានប្រព័ន្ធដំណក់ទឹកសម្រាប់ការស្រោចស្រពដំណាំសមរម្យ។ ក្រៅពីនេះការថែទាំដំណាំក៏មានសារៈសំខាន់ដល់ដំណើរការលូតលាស់របស់ស្ពៃក្តោបផងដែរ ដោយកសិករត្រូវត្រួតពិនិត្យសត្វល្អិតចង្រៃ ជំងឺដំណាំ និងបន្ថែមជីឱ្យសមរម្យស្របតាមតម្រូវការនៃការលូតលាស់។ ប្រសិនបើសង្កេតឃើញមានសត្វល្អិតចង្រៃ កសិករអាចប្រើវិធីធម្មជាតិ វិធានការជីវសាស្ត្រ វិធានការគីមី ដើម្បីការពារដំណាំពីការខូចខាត និងការបំផ្លាញ។ បច្ចុប្បន្នកសិករជាច្រើនបានជំរុញការដាំដុះស្ពៃក្តោបក្នុងផ្ទះសំណាញ់ ដោយសារអាចការពារការបំផ្លាញពីសត្វល្អិតចង្រៃបានល្អប្រសើរ អាចដាំបានគ្រប់រដូវកាល បង្កើនផលិតភាព និងមានលទ្ធភាពចំណេញបានល្អប្រសើរ។